# កំហុស (Culpability)

កំហុស គឺជាគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ (general principle of criminal law)។ វិធានកំហុសនេះ ត្រូវបានចាត់ថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

វាមានប្រភពមកពីវិធានជាច្រើន និងជាពិសេស គឺជាផ្នែកមួយនៃ ធាតុអត្តនោម័ត (*mens rea*)។ ដើម្បីបង្កើតនូវ កំហុស ធាតុផ្សំអត្តនោម័ត ត្រូវបានតម្រូវឲ្យមាន (intent) ឬករណីលើកលែង ត្រឹមតែជាការធ្វេសប្រហែស (negligence)។

មិនមានកំហុសជាបុគ្គលទេ ប្រសិនបើបុគ្គលណាមួយ មិនបានចូលរួម ដោយផ្ទាល់ ឬដោយប្រយោលក្នុងសកម្មភាពល្មើស ដូចជាតាមរយៈការជួយ (aiding)។ ការដាក់ឲ្យបុគ្គលទទួលខុសត្រូវលើសពីនេះ ដូចជា ក្នុងទម្រង់ទទួលខុសត្រូវរបស់មេបញ្ជាការ (command responsibility) ឬសហឧក្រិដ្ឋកម្មរួម (joint criminal enterprise) ត្រូវបានគេមើលថា មិនបានគោរពពេញលេញនៃគោលការណ៍កំហុសជាបុគ្គលនេះទេ។

គោលការណ៍កំហុស ត្រូវបានឆ្លុះបញ្ចាំងផងដែរ ក្នុងការផ្តន្ទាទោស (sentencing)។ ទាំងការដាក់ទោសក្តី ការកំណត់កម្រិតកំហុសក្តី ត្រូវផ្អែកតាម ភាពមានកំហុសស្រដៀងគ្នា (equal culpability) ដោយវាយតម្លៃលើការចូលរួម និងចេតនារបស់អ្នកប្រព្រឹត្ត (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 288-289)។